# សេចក្ដីពន្យល់

# ស្ដីពី

# ក្រមរដ្ឋប្បវេណីកម្ពុជា

# (របបគំរោង)

ដោយលោក Niimi Ikufumi សាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រ

នៃសាកលវិទ្យាល័យ Meiji

រាជធានីភ្នំពេញ ថ្ងៃទី១៥-១៦ ខែកក្កដា ឆ្នាំ២០១១

ថ្ងៃទី ១៥ និង ១៦ កក្កដា ២០១១

# ស្ដីពីក្រមរដ្ឋប្បវេណីកម្ពុជា (របបតំណាង)

លោក Niimi Ikufumi

សាស្ត្រាចារ្យមហាវិទ្យាល័យនីតិសាស្ត្រ សាកលវិទ្យាល័យ Meiji

## 1 អ្វីទៅ តំណាង ?

ក្នុងករណីដែលអ្នកតំណាង A បានធ្វើសកម្មភាពគតិយុត្តនឹងភាគីម្ខាងទៀត O ដោយបង្ហាញថា ខ្លួនបានធ្វើសម្រាប់ P ដោយផ្អែកលើសិទ្ធិដែលខ្លួនបានទទួលពីសាមីខ្លួន P អានុភាពនៃសកម្មភាពគតិយុត្តនោះត្រូវមានចំពោះសាមីខ្លួន P (ក្រមរដ្ឋប្បវេណីកម្ពុជា [ខាងក្រោមនេះ ហៅកាត់ថា CC] មាត្រា 364)។




## 2 សង្គមនៃការតំណាង, មុខងារសេដ្ឋកិច្ច

### 2.1 ការពង្រីកស្វ័យភាពបុគ្គលឯកជន = ការពង្រីក និង ការពង្រឹងទំហំនៃប្រតិបត្តិការ

តាមរយៈការប្រើA P អាចពង្រីកសកម្មភាពរបស់ខ្លួនទាំងដែនសកម្មភាព ទាំងពេលវេលាព្រមជាមួយគ្នានេះ ក៏អាចប្រើនូវចំណេះដឹងឯកទេស និងបច្ចេកទេសរបស់ A បាន។

→ ការតំណាងដោយស្ម័គចិត្ត (ការផ្ដល់សិទ្ធិតាមរយៈកិច្ចសន្យា) CC365

### 2.2 ការបំពេញបន្ថែមនៃស្វ័យភាពបុគ្គលឯកជន = ការការពារជនដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព (អនីតិជន, អ្នកនៅក្រោមអាណាព្យាបាល, អ្នកនៅក្រោមហិតូប

ត្តម្ភ )

បើសិនជា P ពុំមានសមត្ថភាពវិនិច្ឆ័យពេញលេញដោយខ្លួនឯងបានទេ P នឹងបាត់បង់ផលប្រយោជន៍ក្នុងកិច្ចប្រតិបត្តិការក្នុងសង្គមមួយដែលមានការប្រជែងខ្លាំង។ ដូច្នេះតាមរយៈសកម្មភាពរបស់Aដែលបានធ្វើជំនួស P នោះ P អាចប្រតិបត្តិការដោយសមភាពបាន។

→ ការតំណាងកំណត់ដោយច្បាប់ (ការផ្តល់សិទ្ធិដោយច្បាប់ ) CC365

3 ល័ក្ខខ័ណ្ឌបង្កើតការតំណាង

3.1 ការផ្តល់សិទ្ធិតំណាង

ដើម្បីបង្កើតការតំណាង បញ្ហាសំខាន់គឺ សកម្មភាពរបស់ A ត្រូវធ្វើឡើងដោយផ្អែកលើសិទ្ធិមួយស្របច្បាប់ (សិទ្ធិតំណាង)។

សិទ្ធិតំណាង គឺជាមូលដ្ឋានដែលធ្វើឱ្យអានុភាពនៃសកម្មភាពគតិយុត្តរបស់ A (សកម្មភាពតំណាង) ធ្លាក់ទៅលើ P។ សិទ្ធិតំណាងមានពីរប្រភេទគឺ "សិទ្ធិតំណាងដែលស្ម័គចិត្ត" ក្នុងករណីដែល A បានទទួលដោយផ្អែកលើឆន្ទៈរបស់ P (មានន័យថា ដោយផ្អែកលើកិច្ចសន្យារវាង P និង A) និង "សិទ្ធិតំណាងកំណត់ដោយច្បាប់" ក្នុងករណីដែល A បានទទួលដោយផ្អែកលើបញ្ញត្តិច្បាប់។

កិច្ចសន្យាផ្តល់សិទ្ធិតំណាងរវាង P និង A នៃការតំណាងដោយស្ម័គចិត្ត គឺភាគច្រើន កើតមានឡើងតាមរយៈការអាណត្តិ។ ក៏ប៉ុន្តែមិនមែនមានតែការអាណត្តិនេះទេដែលអាចបង្កើតការតំណាងបាន កិច្ចសន្យាការងារ ជាដើម មួយចំនួនក៏អាចជាករណីបង្កើតសិទ្ធិតំណាងដែរ។ ឧទាហរណ៍ ស្តីពីផ្សារទំនើប P ដែលជាម្ចាស់ផ្សារទំនើប អាចជ្រើសតាំងបុគ្គលិកម្នាក់នៃសាខាមួយក្នុងចំណោមសាខាទាំងអស់ ហើយផ្តល់សិទ្ធិឱ្យបុគ្គលិកនោះទិញចូលនូវទំនិញដែលត្រូវបានកំណត់មួយចំនួន។ ក្នុងករណីនេះ អាចចាត់ទុកថា A បានទទួលសិទ្ធិតំណាងក្នុងការទិញទំនិញនោះចូលបាន។ បញ្ហាថា តើមានការផ្តល់សិទ្ធិតំណាងឬទេ គឺជាចំណុចមួយដែលត្រូវពិចារណាដោយមើលតែសកម្មភាពខាងក្រៅ មិនចាំបាច់គិតថា តើកិច្ចសន្យានោះជាប្រភេទណាមួយទេ។

ទោះជា P មិនបានទទួលសិទ្ធិតំណាងក៏ដោយ តែបើសិនជា P បានធ្វើសកម្មភាពគតិយុត្តនឹង O ដើម្បី A តើរវាង P A និង O មានទំនាក់ទំនងគតិយុត្តអ្វីខ្លះកើតមានឡើង ?

គឺជាបញ្ហាតំណាងដោយគ្មានសិទ្ធិ និងបញ្ហាតំណាងដែលមានលក្ខណៈជារូបភាព។ ចំណុច

នេះ នឹងពន្យល់លំអិតខាងក្រោយ។

3.2 គោលការណ៍ប្រកាសថា នឹងធ្វើសកម្មភាពគតិយុត្តឱ្យបុគ្គលដែលខ្លួនតំណាង

ក្នុងការតំណាង គេទាមទារឱ្យ A ប្រកាសថា ខ្លួននឹងធ្វើសកម្មភាពគតិយុត្ត (សកម្មភាពតំណាង) សម្រាប់ P។ នេះគេហៅថា គោលការណ៍ប្រកាសថា នឹងធ្វើសកម្មភាពគតិយុត្តឱ្យបុគ្គលដែលខ្លួនបានតំណាង។ នេះគឺដើម្បីធ្វើឱ្យ O អាចដឹងថា តើអ្នកណាជាភាគីនៃកិច្ចប្រតិបត្តិការនោះ។ នេះគឺជាចំណុចសំខាន់ណាស់សម្រាប់ភាគី។ ដោយសារបញ្ហាថា តើអាចសម្រេចនូវគោលដៅ ឬមិនអាចសម្រេចនោះ (តើនឹងមានការអនុវត្តកិច្ចសន្យានោះពិតប្រាកដឬទេ) ពាក់ព័ន្ធខ្លាំងទៅនឹងសាធនភាពរបស់ភាគីម្ខាងទៀត ឬជំនឿទុកចិត្តទៅលើគាត់។ ម្យ៉ាងទៀត ក្នុងសង្គមប្រតិបត្តិការ តើអ្នកណាជាអ្នកមានទំនាក់ទំនងក្នុងកិច្ចប្រតិបត្តិការនេះ គឺជាកត្តាដ៏សំខាន់មួយដែលធ្វើឱ្យគេជឿទុកចិត្ត។ យើងគួរដឹងថា "សេរីភាពក្នុងការជ្រើសរើសភាគីម្ខាងទៀត" គឺជាខ្លឹមសារមួយដែរនៃគោលការណ៍សេរីភាពនៃកិច្ចសន្យា។

> តើសកម្មភាពគតិយុត្តដែល A បានធ្វើ តែមិនបានបង្ហាញថា ធ្វើសម្រាប់ P នឹងក្លាយទៅជាយ៉ាងណាដែរ ?

ករណីនេះមានចែងក្នុង CC373។

4 ចំណុចដែលត្រូវពិចារណាក្នុងសកម្មភាពតំណាង

4.1 វិការៈនៃសកម្មភាពតំណាង

ក្នុងការធ្វើសកម្មភាពតំណាង ស្តីពីបញ្ហាវិការៈក្នុងការបង្ហាញឆន្ទៈ ដូចជាការភាន់ច្រឡំ ការឆបោក ការគម្រាមកំហែង ជាដើម (សូមមើល CC345) ឬស្តីពីបញ្ហាថា តើអ្នកបង្កើតកិច្ចសន្យាបានទទួលឥទ្ធិពលពីអានុភាពនៃកិច្ចសន្យា ដូចជា ភាពសុចរិត គ្មានកំហុស (ឧទាហរណ៍ CC373) ជាដើម គឺយើងត្រូវធ្វើការវិនិច្ឆ័យទៅលើA។ នេះគឺដោយសារតែ A ជាអ្នកចរចាជាក់ស្តែង ដូច្នេះជាការធម្មតា ត្រូវធ្វើការវិនិច្ឆ័យចំពោះ A នោះ។ ក៏ប៉ុន្តែចំពោះសកម្មភាពអ្វីមួយដែល A បានធ្វើតាមការបញ្ជារបស់ P ត្រូវធ្វើការវិនិច្ឆ័យចំពោះ P ទៅវិញ។ នេះគឺដោយសារតែពេលដែលបានធ្វើសកម្មភាពនោះ ពុំមានការសម្រេចដោយឆន្ទៈរបស់ A ទេ។ សូមមើល CC374។

【កំណត់】 អ្វីទៅ វិការៈក្នុងការបង្ហាញឆន្ទៈ ?

ក្នុងករណីដែលបានបង្កើតកិច្ចសន្យាដោយផ្អែកលើឆន្ទៈរបស់ភាគី នឹងត្រូវមានចំណងតាមផ្លូវច្បាប់។ សុភាសិតមួយនិយាយថា "ត្រូវគោរពការសន្យា" ហើយនេះគឺចំពោះករណីដែលជាសេចក្ដីសម្រេចដោយឆន្ទៈដែលមានសេរីភាព និងការពិចារណាត្រឹមត្រូវរបស់អ្នកសន្យា។ មូលហេតុដែលនឹងរៀបរាប់ខាងក្រោមនេះ គឺជាប្រភេទនៃមូលហេតុដែលមិនមានការសម្រេចដោយឆន្ទៈរបស់ភាគី ឬករណីដែលមានភាពផ្ទុយនឹងការបង្ហាញឆន្ទៈ។ ដូច្នេះ ក្នុងករណីនីមួយៗនេះ គេទទួលស្គាល់នូវការលុបចោលនូវកិច្ចសន្យានោះ ក្រោមល័ក្ខខ័ណ្ឌកំណត់មួយចំនួន។

(i) ការភាន់ច្រឡំ (CC346)

ក្នុងករណីដែលមានការភាន់ច្រឡំស្ដីពីភាគសំខាន់មួយនៃកិច្ចសន្យា ហើយភាគីម្ខាងទៀតអាចដឹងអំពីការភាន់ច្រឡំនោះ អ្នកបង្ហាញឆន្ទៈអាចលុបកិច្ចសន្យានោះចោលបាន (CC346 កថាខ័ណ្ឌទី1)។ តើត្រូវជា "ចំណុចសំខាន់" ឬទេ ជាគោលការណ៍ ត្រូវពិចារណា និងវិនិច្ឆ័យដោយពិចារណាជាក់ស្ដែងដល់ប្រភេទនៃកិច្ចប្រតិបត្តិការ និងស្ថានភាពនានាជុំវិញកិច្ចប្រតិបត្តិការនោះ។ ក្នុងករណីដែលភាគីម្ខាងទៀតនៃកិច្ចសន្យាអាចដឹងបានថា "អ្នកបង្ហាញឆន្ទៈបានគិតឃើញថា ចំណុចនោះសំខាន់ ហើយមានការភាន់ច្រឡំ" គេអាចទទួលស្គាល់នូវការលុបកិច្ចសន្យានោះដោយអ្នកបង្ហាញឆន្ទៈបាន (CC346 កថាខ័ណ្ឌទី2)។ ម្យ៉ាងទៀត ការលុបចោលនេះមិនអាចអះអាងចំពោះតតិយជនដែលសុចរិតនិងគ្មានកំហុសបានឡើយ តែអាចអះអាងចំពោះតតិយជនក្រៅពីនេះបាន (CC346 កថាខ័ណ្ឌទី4)។ នេះគឺដោយសារតែគិតដល់បញ្ហាសុវត្ថិភាពនៃប្រតិបត្តិការ។

(ii) ការឆបោក (CC347)

ក្នុងករណីដែលអ្នកបង្ហាញឆន្ទៈបានបង្ហាញឆន្ទៈដែលមានការភាន់ច្រឡំ ដោយសារតែការឆបោកដោយចេតនារបស់ភាគីម្ខាងទៀត អ្នកបង្ហាញឆន្ទៈអាចលុបចោលនូវការបង្ហាញឆន្ទៈនោះបាន ដោយលើកឡើងនូវមូលហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ (CC347 កថាខ័ណ្ឌទី1) ។ ដើម្បីអាចថា ការបង្ហាញឆន្ទៈនោះមានការភាន់ច្រឡំដោយសារការឆបោក ចាំបាច់ត្រូវមានស្ថានភាពថា បើសិនជាពុំមានការឆបោកនោះទេ ក៏អ្នកនោះមិនបង្ហាញឆន្ទៈហ្នឹងដែរ។ បើសិនជាគ្រាន់តែមានការឆបោកប៉ុណ្ណោះ មិនអាចទទួលស្គាល់ឱ្យលុបចោលបានឡើយ។ ម្យ៉ាងទៀត បើសិនជាការឆបោកនោះជាអំពើធ្វើដោយតតិយជន ត្រូវពិចារណាដល់ភាគីម្ខាងទៀត ហើយត្រូវធ្វើយ៉ាងណាដើម្បីធានានូវសុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការ។ ស្ដីពីបញ្ហាត្រូវគេបោកនោះ មិនមែនខាងអ្នកបង្ហាញឆន្ទៈគ្មានកំហុសទាល់តែសោះទេ ដូច្នេះក្នុងករណីដែលជាការឆបោកដោយតតិយជន គប្បីតែការពារភាគីម្ខាងទៀតដែលសុចរិតនិងគ្មានកំហុស (CC347 កថាខ័ណ្ឌទី 2)។ ការលុបចោលដោយលើកឡើងនូវមូលហេតុឆបោក មិនអាចអះអាងចំពោះតតិយជនដែលសុចរិត

គ្មានកំហុសទេ តែអាចអះអាងចំពោះតតិយជនក្រៅពីនេះបាន (CC347 កថាខ័ណ្ឌទី 3)។

(iii) ការបង្ហាញមិនពិត (CC348)

ក្នុងការឆបោក អាចមានករណីដែលមានការផ្តល់នូវពត៌មានមិនពិតដោយចេតនាចំពោះអ្នកបង្ហាញឆន្ទៈ។ នៅក្នុងកិច្ចប្រតិបត្តិការជាក់ស្តែង អាចមានករណីច្រើន ដែលជាការផ្តល់ពត៌មានមិនពិតពីភាគីម្ខាងទៀត ឬពីតតិយជនដោយអចេតនា។ បើសិនជាមើលពីខាងអ្នកបង្ហាញឆន្ទៈវិញ នេះគឺជាការបង្ហាញឆន្ទៈដោយផ្អែកលើពត៌មានមិនត្រឹមត្រូវ ដូច្នេះវាក៏ដូចគ្នានឹងករណីឆបោកដែរ។ ដូច្នេះហើយ បើសិនជាអ្នកបង្ហាញឆន្ទៈដែលបានបង្ហាញឆន្ទៈដោយផ្អែកលើពត៌មានមិនពិតដែលផ្តល់ដោយភាគីម្ខាងទៀត ច្បាស់ជាមិនបង្ហាញឆន្ទៈបែបនោះទេ បើសិនអ្នកនោះបានទទួលពត៌មានពិត អ្នកបង្ហាញឆន្ទៈនោះអាចលុបចោលនូវកិច្ចសន្យានោះបាន ដោយលើកឡើងនូវមូលហេតុថា មានវិការៈក្នុងការបង្ហាញឆន្ទៈ (CC348 កថាខ័ណ្ឌទី1)។ ស្តីពីបញ្ហាថា “អ្នកនោះនឹងមិនបង្ហាញឆន្ទៈបែបនេះទេ ប្រសិនជាខ្លួនបានទទួលពត៌មានពិត” តើអាចនិយាយបែបនេះឬទេនោះ គឺពាក់ព័ន្ធនឹងបញ្ហាថា តើពត៌មានមិនពិតនោះមានន័យសំខាន់ក្នុងការបង្កើតកិច្ចសន្យានោះដែរឬទេ។ ម្យ៉ាងទៀត នេះគឺខុសនឹងករណីឆបោក គឺមិនត្រូវគិតដល់ការផ្តល់ពត៌មានមិនពិតដោយគ្មានចេតនារបស់តតិយជនទេ។ នេះគឺដោយសារតែក្នុងសង្គមប្រតិបត្តិការ មានពត៌មានមិនពិតជាច្រើន ម្ល៉ោះហើយ បើសិនជាយើងគិតដល់ការផ្តល់ពត៌មានមិនពិតដោយគ្មានចេតនារបស់តតិយជនទៅ នឹងធ្វើឱ្យកិច្ចប្រតិបត្តិការអស្ថិរភាពខ្លាំង។ ម្យ៉ាងទៀត ការលុបចោលនូវកិច្ចសន្យាដោយមូលហេតុពត៌មានមិនពិត ក៏មិនអាចអះអាងចំពោះតតិយជនដែលសុចរិតគ្មានកំហុសបានទេ តែអាចអះអាងបានចំពោះតតិយជនក្រៅពីនេះ (CC348 កថាខ័ណ្ឌទី3)។

ម្យ៉ាងទៀត អ្នកបង្ហាញឆន្ទៈអាចទាមទារសំណងនៃការខូចខាត ចំពោះភាគីម្ខាងទៀតដែលបានផ្តល់ពត៌មានមិនពិតដោយមានកំហុសបាន (CC348កថាខ័ណ្ឌទី2)។ តាមរយៈការលុបចោលនេះ កិច្ចសន្យានឹងមិនបង្កើតអានុភាពទេ ដូច្នេះការទទួលខុសត្រូវនូវសំណងនៃការខូចខាតនេះ គឺជាការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល ក៏ប៉ុន្តែអាចមានការបកស្រាយថា ជាការទទួលខុសពាក់ព័ន្ធនឹងការបង្កើតកិច្ចសន្យា ដែលជាការទទួលខុសត្រូវនៃកិច្ចសន្យាដែរ។ យើងខ្ញុំសង្ឃឹមថា តាមរយៈករណីយុត្តិសាស្ត្រ និងទស្សនៈនៃអ្នកស្រាវជ្រាវ កម្ពុជាច្បាស់ជានឹងបង្កើតទ្រឹស្តីនេះដោយខ្លួនឯងបាន។

ក្នុងករណីដែលភាគីម្ខាងទៀតបានផ្តល់ពត៌មានមិនពិតដោយសុចរិតហើយគ្មានកំហុស តែអ្នកបង្ហាញឆន្ទៈបានជឿថា ជាពត៌មានពិត ហើយបានបង្កើតកិច្ចសន្យា តែអ្នកបង្ហាញឆន្ទៈនោះមានកំហុស តើអ្នកនោះអាចលុបកិច្ចសន្យានោះចោលបានដែរឬទេ ? បើសិនជាអាចលុបបាន

ស្តីពីផលប្រយោជនដែលភាគីម្ខាងទៀតបានបាត់បង់នោះ តើត្រូវគិតយ៉ាងណាដែរចំពោះការបាត់បង់នូវផលប្រយោជន៍របស់ភាគីម្ខាងទៀត ?

(iv) ការគម្រាមកំហែង (CC350)

គេទទួលស្គាល់នូវអានុភាពចងក្នុងកិច្ចសន្យា ដោយសារតែនេះគឺជាការទទួលបន្ទុកនូវកាតព្វកិច្ចតាមរយៈការធ្វើសេចក្តីសម្រេចដោយសេរីរបស់អ្នកសន្យា (ភាគច្រើន គឺជាការប្តូរនឹងការធ្វើលទ្ធកម្មនូវសិទ្ធិអ្វីមួយ)។ គោលការណ៍មូលដ្ឋាននៃសេដ្ឋកិច្ចទីផ្សារគឺ ការប្រជែងដោយសេរី ហើយបើសិនជាមានការប្រជែងដោយពុំមានសេរីភាពក្នុងការធ្វើសេចក្តីសម្រេច (ការបង្កើតកិច្ចសន្យា) ទេនោះ វានឹងឃ្លាតចាកពីគោលការណ៍នេះហើយ។ ហេតុនេះហើយ កិច្ចសន្យាណាដែលត្រូវបានបង្កើតឡើងដោយពុំមានការសម្រេចសេចក្តីដោយសេរីទេនោះ មិនត្រូវទទួលស្គាល់នូវអានុភាពចំណងនេះទេ។ ករណីដែលមិនអាចទទួលស្គាល់នូវសេចក្តីសម្រេចដោយសេរីមានដូចជា ករណីដែលភាគីម្ខាងទៀតបានគម្រាមកំហែង ឬបង្ខំឱ្យបង្ហាញឆន្ទៈ។ ការបង្ហាញឆន្ទៈដោយការគម្រាមកំហែងខុសពីករណីឆបោក គឺមិនមានការទទួលស្គាល់នូវកំហុសរបស់អ្នកបង្ហាញឆន្ទៈទេ ហេតុនេះហើយ ទោះជាករណីដែលជាការគម្រាមកំហែងដោយភាគីម្ខាងទៀតក៏ដោយ ឬជាករណីដែលជាការគម្រាមកំហែងដោយតតិយជនក៏ដោយ អ្នកបង្ហាញឆន្ទៈអាចលុបកិច្ចសន្យាចោលដោយលើកឡើងនូវមូលហេតុថាមានវិការៈក្នុងការបង្ហាញឆន្ទៈដោយការគម្រាមកំហែង (CC350) (ចូរប្រៀបធៀបនឹងករណីឆបោកដោយតតិយជន)។ម្យ៉ាងទៀត ការលុបចោលនេះអាចអះអាងចំពោះតតិយជនបាន ទោះជាតតិយជននោះបានដឹង ឬមិនដឹងក៏ដោយ។ ក្នុងនេះ ពុំមានបញ្ញត្តិណាចែងច្បាស់ទេ តែស្តីពីការឆបោក ជាអាទ៍ មានបញ្ញត្តិចែងអំពីអានុភាពចំពោះតតិយជន រីឯស្តីពីការគម្រាមកំហែងវិញ ពុំមានបញ្ញត្តិបែបនេះទេ។ លើសពីនេះ ការលុបចោលមានអានុភាពប្រតិសកម្មក្នុងការបដិសេធកិច្ចសន្យានោះ ដូច្នេះគប្បីតែបកស្រាយបែបនេះ។ ស្តីពីចំណុចនេះ ក៏ខុសនឹងករណីឆបោកដែរ។ បើសិនជាគិតដល់ស្ថិរភាពនៃកិច្ចប្រតិបត្តិការ ករណីនេះអាចធ្វើឱ្យខូចផលប្រយោជន៍ចំពោះតតិយជនបានដោយគ្មានការព្រាងទុក។ ក៏ប៉ុន្តែការគម្រាមកំហែងគឺជាអំពើមួយដែលមិនអាចអនុញ្ញាតបានក្នុងសេដ្ឋកិច្ចទីផ្សារ ដូច្នេះត្រូវការពារជនរងគ្រោះដោយសារអំពើនេះជាមុន។

(v) ការរំលោភបំពានលើស្ថានភាព(CC349)

មូលហេតុដែលមិនអាចសម្រេចដោយសេរីដែលមានច្រើនគឺ ការគម្រាមកំហែង ។ ក្រៅពីនេះ ទោះជាពុំមានការគម្រាមកំហែងពីភាគីម្ខាងទៀត ឬពីតតិយជនក៏ដោយ ក៏អាចមានករណីដែល

អ្នកបង្ហាញឆន្ទៈមិនអាចធ្វើសេចក្តីសម្រេចដោយឆន្ទៈសេរីរបស់ខ្លួនបាន ដោយសារតែស្ថានភាពសង្គម ឬស្ថានភាពសេដ្ឋកិច្ចដែរ។ ក្នុងករណីដែលជនទន់ខ្សោយខាងវិស័យសេដ្ឋកិច្ចធ្វើកិច្ចសន្យានឹងអ្នកដែលមានឋានៈខ្ពស់មានអំណាចខ្លាំងជាង អាចមានករណីដែលខ្លឹមសារនៃកិច្ចសន្យានោះផ្តល់អាទិភាពទៅខាងអ្នកមានឋានៈខ្ពស់អំណាចខ្លាំងនោះ។ ក្នុងករណីបែបនេះ គប្បីទទួលស្គាល់នូវសិទ្ធិលុបកិច្ចសន្យានោះចោលដោយជនទន់ខ្សោយ ដោយមូលហេតុគ្មានសេចក្តីសម្រេចឆន្ទៈដោយសេរី។ ក៏ប៉ុន្តែជាក់ស្តែង ការចរចារអំពីប្រតិបត្តិការដែលភាគីទាំងសងខាងមានភាពស្មើគ្នាមានតិចតួចទេ គឺច្រើនតែគ្មានតុល្យភាព។ ភាគច្រើន គឺមានភាពលំអៀងទៅភាគីខ្លាំង។ តែប្រសិនបើជនទន់ខ្សោយអាចលុបកិច្ចសន្យានោះចោលគ្រប់ពេលដោយមូលហេតុប្រតិបត្តិការរវាងអ្នកមានឋានៈខ្ពស់អំណាចខ្លាំងនិងអ្នកទន់ខ្សោយទៅ នឹងអាចធ្វើឱ្យសង្គមប្រតិបត្តិការមានការជ្រួលច្របល់។ ហេតុនេះហើយ CC349 កថាខ័ណ្ឌទី 1 បានបញ្ញត្តិថា ពេលដែលអ្នកមានឋានៈខ្ពស់អំណាចខ្លាំងបានប្រើឋានៈរបស់ខ្លួនដែលមានអាទិភាពជាងភាគីម្ខាងទៀត ក្នុងសង្គម ឬក្នុងវិស័យសេដ្ឋកិច្ច "ប្រើស្ថានភាពផ្សេងទៀតមិនត្រឹមត្រូវ" ដែលភាគីម្ខាងទៀតនោះមិនអាចប្រឆាំងតបវិញបាន ភាគីដែលទន់ខ្សោយអាចលុបចោលនូវកិច្ចសន្យានោះបាន។ ការកំណត់ថា អំពើណាមួយជាអំពើមិនត្រឹមត្រូវ ឬត្រឹមត្រូវ គឺមានការពិបាកខ្លាំងណាស់។ តើត្រូវហាមមិនឱ្យប្រើស្ថានភាពបែបណា ឬឋានៈយ៉ាងណា គឺត្រូវពិចារណាទៅតាមសង្គមនីមួយៗនោះ ដូច្នេះត្រូវធ្វើការវិនិច្ឆ័យទៅតាមករណីយុត្តិសាស្ត្រ។ម្យ៉ាងទៀត ការលុបកិច្ចសន្យាចោលដោយសារការប្រើបំពាននូវស្ថានភាពនេះ ក៏មិនអាចអះអាងចំពោះតតិយជនដែលសុចរិតនិងគ្មានកំហុសបានឡើយ តែអាចអះអាងចំពោះតតិយជនក្រៅពីនេះបាន (CC349 កថាខ័ណ្ឌទី 2)។

(vi) អំពើកេងយកចំណេញហួសហេតុ (CC351)

សេចក្តីសម្រេចដោយឆន្ទៈសេរី និងដោយមានការពិចារណាលំអិត គឺជាមូលដ្ឋាននៃអានុភាពចងនៃកិច្ចសន្យា (ការសន្យា) នោះ។ ដូច្នេះ ប្រសិនជាមានការសម្រេចឆន្ទៈបែបនេះ ទោះជាភាគីម្ខាងនៃកិច្ចសន្យាបានទទួលផលប្រយោជន៍សន្ធឹកសន្ធាប់ក៏ដោយ ក៏មិនអាចចាត់ទុកថាមិនត្រឹមត្រូវទេ ហេតុនេះហើយ ពុំមានមូលហេតុអ្វីដែលត្រូវបដិសេធនូវអានុភាពនៃកិច្ចសន្យានោះទេ។ ក៏ប៉ុន្តែក្នុងករណីដែលការទទួលនូវផលប្រយោជន៍សន្ធឹកសន្ធាប់នេះ បានមកពីកិច្ចសន្យាដែលបានធ្វើឡើងក្នុងស្ថានភាពពិបាកធ្ងន់ធ្ងរ ឬមិនដឹងអ្វីរបស់ភាគីម្ខាងទៀត សង្គមមិនអាចអនុញ្ញាតបានឡើយ។ដូច្នេះ CC351បានចែងថា ក្នុងករណីដែលភាគីម្ខាងបានធ្វើកិច្ចសន្យា ដោយឆ្លៀតឱកាសដែលភាគីម្ខាងទៀត កំពុងជួបប្រទះការលំបាកខាងផ្នែកសេដ្ឋកិច្ច ឬ ភាពល្ងង់ ឬ ការខ្វះការពិសោធន៍ ហើយ បានកេងយកចំណេញយ៉ាងសន្ធឹកសន្ធាប់ពីកិច្ចសន្យានោះ ភាគីម្ខាងទៀតនោះអាចលុបកិច្ចសន្យាចោលបាន ដោយហេតុថា ការបង្ហាញឆន្ទៈនោះមានវិការៈ។ តើផល

ប្រយោជន៍ដែលបានទទួលនោះ ជាផលប្រយោជន៍សន្ទឹកសន្ទាប់ឬទេ គឺខុសៗគ្នាទៅតាមស្ថានភាពនៃសម័យកាល ឬសង្គម ដូច្នេះត្រូវធ្វើការវិនិច្ឆ័យទៅតាមទម្លាប់នៃសង្គម ឬទម្លាប់នៃប្រតិបត្តិការនាពេលនីមួយៗនោះ។

(vii) ឋបនីយផ្លូវចិត្ត (CC352)

ការបង្ហាញឆន្ទៈដែលគេដឹងថា ជាឆន្ទៈដែលមិនមែនជាសេចក្តីសម្រេចពិត ដូចជាករណីដែលបានធ្វើកិច្ចសន្យាដោយលេងសើចជាដើម គឺជាការបង្ហាញឆន្ទៈដែលមានកង្វះមូលដ្ឋាននៃអានុភាពចងភាគី។ ក៏ប៉ុន្តែតាមធម្មតា ភាគីម្ខាងទៀតមិនបានដឹងអំពីបញ្ហានេះទេ ដូច្នេះបើសិនជាគិតដល់សុវត្ថិភាពនៃប្រតិបត្តិការ ជាគោលការណ៍ អ្នកបង្ហាញឆន្ទៈមិនអាចបដិសេធនូវអានុភាពនៃកិច្ចសន្យាដែលខ្លួនបានបង្កើតឡើងខុសនឹងឆន្ទៈពិតរបស់ខ្លួនបានទេ (CC352 វាក្យខ័ណ្ឌទី 1)។ តែបើសិនជាភាគីម្ខាងទៀតបានដឹង ឬមានស្ថានភាពត្រូវដឹងថា កិច្ចសន្យានោះមិនមែនជាកិច្ចសន្យាដែលត្រូវបានធ្វើឡើងដោយឆន្ទៈពិត មិនចាំបាច់រក្សានូវអានុភាពចងនៃកិច្ចសន្យានោះទេ។ យើងអាចទទួលស្គាល់នូវសិទ្ធិលុបកិច្ចសន្យាចោលដោយអ្នកបង្ហាញឆន្ទៈ ដោយលើកឡើងនូវមូលហេតុថា មានកង្វះនូវមូលដ្ឋាននៃអានុភាពចងភាគី។ ក៏ប៉ុន្តែបើសិនជាគិតដល់ករណីដែលមានវត្តមានតតិយជន តើការទទួលស្គាល់នូវសិទ្ធិលុបកិច្ចសន្យាចោលនេះត្រឹមត្រូវដែរឬទេ ? ទោះជាកិច្ចសន្យានោះត្រូវបានបង្កើតឡើងដោយខុសពីឆន្ទៈពិតក៏ដោយ តែដោយសារអ្នកបង្ហាញឆន្ទៈបានដឹង ហើយនៅតែបង្កើតកិច្ចសន្យានោះ ដូច្នេះត្រូវរក្សានូវអានុភាពនៃកិច្ចសន្យានោះដដែល ហើយគ្រាន់តែអនុញ្ញាតឱ្យអ្នកបង្ហាញឆន្ទៈនោះអាចបដិសេធនូវការអនុវត្តកិច្ចសន្យាបាន (CC352 វាក្យខ័ណ្ឌទី2)។ ម្យ៉ាងទៀត បើសិនជាតតិយជនបានដឹង ឬមានស្ថានភាពអាចដឹងបានថា កិច្ចសន្យានោះត្រូវបានបង្កើតឡើងដោយឆន្ទៈមិនពិតរបស់អ្នកបង្ហាញឆន្ទៈទៅវិញ តើត្រូវគិតយ៉ាងណាដែរ? ចំពោះបញ្ហានេះ ត្រូវពិចារណាថែមទៀត។ តើអាចបដិសេធនូវការអនុវត្តចំពោះតតិយជនបែបនេះ ឬក៏មិនអនុញ្ញាតឱ្យតវ៉ាចំពោះតតិយជននោះ ? បើសិនជាអនុញ្ញាតឱ្យបដិសេធនូវការអនុវត្ត យើងនឹងទទួលនូវលទ្ធផលដូចគ្នានឹងករណីដែលតតិយជនបានលុបចោលនូវកិច្ចសន្យាក្នុងករណីមានវិការៈក្នុងការបង្ហាញឆន្ទៈ ក្រៅពីការគម្រាមកំហែង។ តែបើសិនជាយើងគិតតាមគោលការណ៍អានុភាពដោយសាបេក្ខ (relative) នៃកិច្ចសន្យាវិញ គឺមិនត្រូវអនុញ្ញាតឱ្យតវ៉ាចំពោះតតិយជនទេ។ សូមខាងកម្ពុជាពិចារណាដើម្បីជ្រើសរើសនូវចម្លើយណាមួយ។

(viii) ការបង្ហាញឆន្ទៈមិនពិត (CC353)

ក្នុងករណីដែលភាគីទាំងសងខាងបានឃុបឃិត ហើយបង្កើតនូវកិច្ចសន្យាដោយផ្អែកលើការ

បង្ហាញឆន្ទៈមិនពិត មិនចាំបាច់ទទួលស្គាល់នូវអានុភាពនៃកិច្ចសន្យានោះទេ (CC353 កថាខ័ណ្ឌទី1)។ ក៏ប៉ុន្តែក្នុងករណីដែលមានវត្ថុមានរបស់តតិយជនដែលមានពាក់ព័ន្ធនឹងផលប្រយោជន៍នៃកិច្ចសន្យានោះ ប្រសិនជាយើងនៅតែបដិសេធនូវអានុភាពនៃកិច្ចសន្យានោះទៅ នឹងអាចធ្វើឱ្យតតិយជននោះខូចប្រយោជន៍ដោយមិនអាចព្រៀងទុកជាមុនបាន។ ដូច្នេះ ចំពោះតតិយជននេះ ប្រសិនជាគាត់គ្មានគំនិតទុច្ចរិត ឬគ្មានកំហុសទេ គប្បីតែកុំឱ្យអះអាងនូវមោឃៈភាពនៃកិច្ចសន្យាចំពោះតតិយជននោះ (CC353 កថាខ័ណ្ឌទី2)។ ស្តីពីករណីដែលតតិយជនមានកំហុសស្រាល អាចមានការពិចារណាថា តើគួរការពារដែរឬទេ។ ក៏ប៉ុន្តែ ការដែលភាគីទាំងសងខាងនៃកិច្ចសន្យាបានឃុបឃិតគ្នាបង្កើតកិច្ចសន្យាមិនពិត គឺជាអំពើខូចខ្លាំងសម្រាប់តតិយជន ដូច្នេះ បើសិនជាអនុវត្តមាត្រានេះចំៗតែម្តងទៅ ទោះជាតតិយជនមានកំហុសស្រាលក៏ដោយ ក៏គប្បីការពារតតិយជនដែរ។ ក៏ប៉ុន្តែបើសិនជាយើងអនុវត្តមាត្រានេះដោយសទិសភាព (analogy) វិញ អាចមានករណីដែលមិនចាំបាច់ការពារតតិយជនដែរ ទៅជាតតិយជននោះមានកំហុសស្រាលក៏ដោយ។

- កំហុស
  - កំហុសជាក់ស្តែង (ការមិនបានប្រយ័ត្ននៃជនពិសេស)
  - កំហុសអរូបី (ការមិនបានប្រយ័ត្ននៃជនធម្មតា (ជនមានវិចារណញ្ញាណ))
    - កំហុសស្រាល
    - កំហុសធ្ងន់ធ្ងរ

ស្តីពីការអនុវត្តដោយសទិសភាពនៃមាត្រា 353 ក្នុងក្រមរដ្ឋប្បវេណីកម្ពុជា តើមានករណីណាខ្លះដែលត្រូវអនុវត្តបែបនេះ? នៅជប៉ុន គេមិនទទួលស្គាល់នូវអានុភាពនៃជំនឿទុកចិត្តទៅលើភាពជាសាធារណៈនៃការចុះបញ្ជី ហេតុនេះហើយ គេបានប្រើបច្ចេកទេសនៃការបកស្រាយបែបនេះដើម្បីបំបាត់នូវភាពមិនសមនេះ។ រីឯនៅកម្ពុជាវិញ តើយ៉ាងណាដែរ ?

### 4.2 អំពើរបស់អ្នកតំណាង

ទោះជា A ជាអ្នកដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពក៏ដោយ ក៏ P អាចជ្រើសតាំងឱ្យ A ធ្វើជាអ្នកតំណាងរបស់ខ្លួនបានដែរ ហើយអំពើតំណាងរបស់ A អាចមាន

អានុភាព (CCC375)។

នេះគឺដោយសារតែអានុភាពនៃសកម្មភាពតំណាងរបស់ A មិនមែនជារបស់ A ទេ ដូច្នេះមិនចាំបាច់គិតដល់បញ្ហាការពារ A ទេ។ ប្រសិនបើ P បានជ្រើសរើស A ឱ្យធ្វើជាតំណាងរបស់ខ្លួនហើយ យើងត្រូវគោរពឆន្ទៈរបស់ P ហើយក៏ស្របនឹងគោលការណ៍ស្វ័យភាពបុគ្គលឯកជនដែរ។ ម្យ៉ាងទៀត ក្នុងករណីដែលជាតំណាងដោយអាណត្តិ យើងអាចលើកយកមូលហេតុនេះមកជាការគ្រប់គ្រាន់ ក៏ប៉ុន្តែបើសិនជាករណីនៃការតំណាងដែលច្បាប់កំណត់ទៅវិញ គឺអាចមានបញ្ហា។ ដូច្នេះ អាចមានមតិថា ក្នុងករណីនៃការតំណាងដែលច្បាប់កំណត់ មិនត្រូវទទួលស្គាល់នូវការជ្រើសតាំងអ្នកដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពទេ។ ក៏ប៉ុន្តែក្នុងករណីនៃការតំណាងដែលច្បាប់កំណត់ ច្បាប់ដែលបញ្ញត្តិស្តីពីការតំណាងដែលច្បាប់កំណត់នោះត្រូវចែងអំពីបញ្ហាជ្រើសតាំងអ្នកតំណាងនេះ។ ហើយប្រសិនជាច្បាប់នោះទទួលស្គាល់នូវការជ្រើសតាំងអ្នកដែលត្រូវបានកម្រិតនូវសម្ថត្ថភាពក្នុងការធ្វើសកម្មភាព យើងក៏ត្រូវអនុវត្តតាមដែរ។

### 4.3 អនុតំណាង

អនុតំណាង គឺជាសកម្មភាពតំណាងជំនួសអ្នកតំណាង។ មានន័យថាAបានឱ្យA′ធ្វើសកម្មភាពតំណាងជំនួសខ្លួន។

ក្នុងការតំណាងដោយអាណត្តិ Pមានទំនុកចិត្តទៅលើA បានជាគាត់ឱ្យAធ្វើសកម្មភាពតំណាងជំនួសគាត់ ហើយជាគោលការណ៍ អនុតំណាងគឺជាអំពើមួយដែលក្បត់នូវទំនុកចិត្តនោះ ដូច្នេះមិនអាចអនុញ្ញាតឱ្យបានទេ។ CC376 បានហាមនូវការជ្រើសតាំងអនុតំណាងក៏ដោយសារមូលហេតុនេះដែរ។

ក្នុងករណីដែលទោះជាមានការហាមឃាត់ក៏ដោយ ហើយនៅតែជ្រើសតាំងអនុតំណាង តើអានុភាពនៃសកម្មភាពតំណាងដោយអនុតំណាងនោះក្លាយទៅជាយ៉ាងណាដែរ ?

CC377 កថាខ័ណ្ឌទី 3

ក៏ប៉ុន្តែ អាចមានករណីដែលមានការអនុញ្ញាតឱ្យជ្រើសតាំងអនុតំណាងក្នុងកិច្ចសន្យាផ្តល់សិទ្ធិតំណាង ឬករណីដែលមានការយល់ព្រមឱ្យជ្រើសតាំងអនុតំណាងដោយ P សម្រាប់ករណីពិសេសនីមួយៗ។ ម្យ៉ាងទៀត អាចមានករណីដែលមិនអាចជៀសវាងបាននូវការជ្រើសតាំងអនុតំណាងក៏មានដែរ។ ក្នុងករណីពិសេសបែបនេះ គេអនុញ្ញាតពិសេសឱ្យជ្រើសតាំងអនុតំណាង

(CC376 វាក្យខ័ណ្ឌទី 2)។

ក្នុងករណីដែលមានការអនុញ្ញាតនូវការជ្រើសតាំងអនុតំណាង A′ ក៏មានឋានៈដូចគ្នានឹងA ដែរ (CC378)។

ក្នុងករណីដែលមានការអនុញ្ញាតឱ្យជ្រើសតាំងអនុតំណាង Aត្រូវទទួលខុសត្រូវចំពោះP ក្នុងការជ្រើសតាំង និងត្រួតពិនិត្យ A′នេះ។ ក៏ប៉ុន្តែប្រសិនជា P ជាអ្នកជ្រើសតាំង A' ទៅវិញ Aត្រូវទទួលខុសត្រូវនូវអំពើរបស់ A′ តែក្នុងករណីដែលខ្លួនបានដឹងថា A′ មិនសមជាអនុតំណាង ឬមិនស្មោះត្រង់ ហើយ Aមិនបានជូនដំណឹងនេះទៅឱ្យP ឬក៏មិនបានដកA′ពីអនុតំណាង (CC377 កថាខ័ណ្ឌទី 1 និងទី 2)។

5 ចំណុចដែលត្រូវពិចារណាស្តីពីសិទ្ធិតំណាង

5.1 ទំហំនៃសិទ្ធិតំណាង

ស្តីពីទំហំដែលសិទ្ធិតំណាងមានឥទ្ធិពល តាមធម្មតា ក្នុងការតំណាងដោយអាណត្តិ គឺមានឥទ្ធិពលទៅលើអំពើដែលបានទទួលសិទ្ធិតំណាង រីឯក្នុងការតំណាងដែលច្បាប់កំណត់វិញ គឺឥទ្ធិពលមានចែងដោយច្បាប់។ ក៏ប៉ុន្តែ ក្នុងករណីដែលពុំមានការកំណត់នូវទំហំនៃសិទ្ធិតំណាងនេះទេ សិទ្ធិតំណាងមានឥទ្ធិពលទៅលើតែ "អំពើថែរក្សា" និង "អំពើកែលំអដែលមិនផ្លាស់ប្តូរលក្ខណៈនៃវត្ថុ ឬសិទ្ធិ" ប៉ុណ្ណោះ (CC366)។

បើសិនជាសិទ្ធិអំណាចនោះមិនច្បាស់លាស់ទេ ហើយអនុញ្ញាតឱ្យAធ្វើអំពើដែលផ្លាស់ប្តូរខ្លាំងពីស្ថានភាពបច្ចុប្បន្ននេះទៅ Pនឹងអាចបាត់បង់ផលប្រយោជន៍ដ៏ធ្ងន់ធ្ងរបាន។ ទោះជាអំពើកែលំអនោះពុំបានផ្លាស់ប្តូរវត្ថុ ឬសិទ្ធិក៏ដោយ តែបើសិនជាចំណាយនោះអស់ច្រើន ក៏មិនត្រូវបញ្ចូលអំពើកែលំអនោះទៅក្នុងទំហំនៃសិទ្ធិតំណាងដែរ ដោយសារតែមូលហេតុដូចគ្នានេះ។

5.2 ការកម្រិតសិទ្ធិតំណាង＝ការហាមនូវអំពើដែលមានផលប្រយោជន៍ផ្ទុយគ្នា (ការតំណាងឱ្យភាគីទាំងសងខាង និងការតំណាងឱ្យខ្លួនឯងហើយធ្វើកិច្ចសន្យានឹងសាមីខ្លួន )

Aត្រូវប្រតិបត្តិការនឹងOក្នុងឋានៈរបស់P។ Aមិនត្រូវធ្វើអំពើអ្វីដែលផ្ទុយនឹងផលប្រយោជន៍របស់Pជាដាច់ខាត។ ក្នុងករណីដែលអំពើរបស់Aផ្ទុយនឹងផលប្រយោជន៍របស់P ហើយគ្មានការយល់ព្រមពីPទេ មិនអាចចាត់ទុកថា មានសិទ្ធិតំណាងបានទេ (CC367 កថាខ័ណ្ឌទី 1)។

យើងត្រូវបកស្រាយថា ផលប្រយោជន៍ក្នុងនេះ មិនមែនត្រឹមតែផលប្រយោជន៍ខាងសេដ្ឋកិច្ចប៉ុណ្ណោះទេ គឺមានរួមទាំងផលប្រយោជន៍ផ្សេងៗទៀត។

បញ្ហាផលប្រយោជន៍ផ្ទុយគ្នា ឬមិនផ្ទុយនេះ មានពាក់ព័ន្ធខ្លាំងនឹងស្ថានភាពជាក់ស្តែងនៃករណីនីមួយៗ។ ក៏ប៉ុន្តែ ក្នុងប្រតិបត្តិការរវាង P និង A (តំណាងឱ្យខ្លួនឯងហើយធ្វើកិច្ចសន្យានឹង

សាមីខ្លួន) ឬប្រតិបត្តិការដែលAមិនត្រឹមតែតំណាងឱ្យតែPទេ គឺជាតំណាងឱ្យ O ថែមទៀត (ការតំណាងឱ្យភាគីទាំងសងខាង) ជាអាទ៍ គឺ A បានធ្វើអំពើសម្រាប់ភាគីដែលមានទំនាក់ទំនងក្នុងការប្រជែង ឬក្នុងនាមជាអ្នកតំណាងនោះ ដូច្នេះ គេសន្មតថា មិនត្រឹមត្រូវទេ (CC367 កថាខ័ណ្ឌទី 2 និងទី 3)។

5.3 ការរលត់នៃសិទ្ធិតំណាង

ក្នុងការតំណាងដោយអាណត្តិ សិទ្ធិតំណាងដោយអាណត្តិត្រូវរលត់ (ក) ក្នុងករណីដែលមានមូលហេតុរលត់សិទ្ធិតំណាងដែលបានកំណត់ក្នុងកិច្ចសន្យាផ្តល់សិទ្ធិតំណាង (CC368 កថាខ័ណ្ឌទី 1 ចំណុច គ.), (ខ) សាមីខ្លួនបានទទួលមរណភាព, ធនក្ស័យ ឬការរំលាយរបស់ម្ចាស់សិទ្ធិ, ព្រមទាំង (គ) អ្នកតំណាងបានទទួលមរណភាព, ធនក្ស័យ ឬត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាព (CC368 កថាខ័ណ្ឌទី 1 ចំណុច ក., ខ.)។

យោងតាមគោលការណ៍ស្វ័យភាពបុគ្គលឯកជន (សេរីភាពក្នុងការបង្កើតកិច្ចសន្យា) គេទទួលស្គាល់នូវចំណុច (ក) ។

បន្ទាប់មក សូមពិចារណាអំពីករណី (ខ)។ មរណភាពរបស់សាមីខ្លួននឹងរំលត់សិទ្ធិតំណាងនៃការតំណាងដោយអាណត្តិនេះ ដោយយោងទៅតាមមូលដ្ឋាននៃទំនាក់ទំនងទំនុកចិត្តរវាងសន្តតិជននិងអ្នកតំណាង។ បើសិនជាភាគីម្ខាងនៃទំនាក់ទំនងទំនុកចិត្តបានទទួលមរណភាព ទំនាក់ទំនងទំនុកចិត្តរវាងសាមីខ្លួននិងអ្នកតំណាងក៏រលាយដែរ។ ណាមួយ ទំនាក់ទំនងទំនុកចិត្តរវាងសន្តតិជននិងអ្នកតំណាងក៏មិនអាចចាត់ទុកថា បានកើតមានឡើងទេ ហេតុនេះហើយ សិទ្ធិតំណាងក៏ត្រូវរលត់ដែរ។ ប្រសិនជាចង់បន្តការតំណាងនោះ ចាំបាច់ត្រូវបង្កើតកិច្ចសន្យាផ្តល់សិទ្ធិតំណាងជាថ្មីទៀតជាមួយនឹងសន្តតិជន។ ក្នុងករណីដែលសាមីខ្លួនជាក្រុមហ៊ុន ហើយក្រុមហ៊ុននោះត្រូវបានរំលាយ ក៏ដូចគ្នានឹងករណីមរណភាពនេះដែរ គឺសិទ្ធិតំណាងនឹងត្រូវរលត់។ ម្យ៉ាងទៀត ក្នុងករណីដែលសាមីខ្លួនបានធនក្ស័យ ការគ្រប់គ្រងនិងការទូទាត់ទ្រព្យសម្បត្តិត្រូវស្ថិតនៅក្រោមអ្នកគ្រប់គ្រងទ្រព្យសម្បត្តិធនក្ស័យ ហេតុនេះហើយ ការទុកឱ្យអ្នកតំណាងនៅដដែលមិនសមរម្យទេ។ ម្ល៉ោះហើយ ក្នុងករណីនេះ ធនក្ស័យរបស់សាមីខ្លួន គឺជាមូលហេតុនៃការរលត់សិទ្ធិតំណាង។

បន្ទាប់មក សូមពិចារណាករណី (គ) វិញ។ មរណភាពរបស់អ្នកតំណាងនឹងរំលត់សិទ្ធិតំណាងដោយសារមូលហេតុដូចគ្នាដែលបានពន្យល់ក្នុងករណីមរណភាពរបស់សាមីខ្លួនដែរ។ ក្នុងករណីដែលអ្នកតំណាងធនក្ស័យវិញ គេលែងជឿទុកចិត្តទៅលើសមត្ថភាពគ្រប់គ្រងទ្រព្យរបស់អ្នកតំណាង ដូច្នេះអ្នកនោះនឹងមានកង្វះនូវលក្ខណៈសម្បត្តិជាអ្នកតំណាង ហេតុនេះហើយ ត្រូវរំលត់សិទ្ធិតំណាងនោះ។ ប្រសិនជាសាមីខ្លួនគិតឃើញថា ធនក្ស័យរបស់អ្នកតំណាងនោះគ្មាន

បញ្ហាចំពោះគាត់ទេ គាត់អាចផ្តល់សិទ្ធិតំណាងជាថ្មីបាន។ ក្នុងករណីដែលបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពរបស់សាមីខ្លួន តុលាការបានយល់ឃើញថា សមត្ថភាពនៃការវិនិច្ឆ័យរបស់អ្នកនោះមានបញ្ហា ហេតុនេះហើយ ការរំលត់សិទ្ធិតំណាងគឺជាការត្រឹមត្រូវ។ ប្រសិនជាសាមីខ្លួនចង់យកអ្នកដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពមកធ្វើជាតំណាង គឺអាចផ្តល់សិទ្ធិតំណាងទៅឱ្យអ្នកនោះជាថ្មីទៅបានហើយ។ គេទទួលស្គាល់នូវការជ្រើសតាំងអ្នកដែលត្រូវបានកម្រិតនូវសមត្ថភាពក្នុងការធ្វើសកម្មភាពជាថ្មីនេះ ដោយសារមូលហេតុដូចដែលបានពន្យល់មុននេះ (សូមមើលវគ្គ 4.2)។

## 6 ការតំណាងដោយគ្មានសិទ្ធិ

### 6.1 អ្វីទៅ ការតំណាងដោយគ្មានសិទ្ធិ ?

ក្នុងករណីដែលAពុំមានសិទ្ធិតំណាង តែបានធ្វើអំពើតំណាង គេហៅថា ការតំណាងដោយគ្មានសិទ្ធិ។ ដោយសារតែគ្មានសិទ្ធិតំណាង ម្ល៉ោះហើយ អានុភាពនៃអំពើតំណាងនោះពុំមែនជារបស់ P ទេ។ក៏ប៉ុន្តែ អាចមានករណីដែល P ចង់ទទួលនូវអានុភាពនោះដែរ។ បើសិនជាទទួលស្គាល់ថា អានុភាពនោះជារបស់ P O នឹងទទួលបាននូវលទ្ធផលដែលខ្លួនចង់បានពីដំបូង ដូច្នេះពុំមានបញ្ហាអ្វីទេ។ ម្ល៉ោះហើយ ក្រមនេះបានផ្តល់ឱកាសឱ្យ P ទទួលស្គាល់នូវការទទួលយក(ផ្តល់សច្ចានុមតិ) អានុភាព ហើយបើសិនជា Pបានផ្តល់សច្ចានុមតិ ករណីនោះនឹងមានភាពដូចគ្នានឹងករណីនៃការតំណាងដោយមានសិទ្ធិដែរ គឺអានុភាពគតិយុត្តនៃអំពើតំណាងនោះនឹងធ្លាក់ទៅលើ P ហើយបើសិនជាមិនផ្តល់សច្ចានុមតិទេ គឺគេបដិសេធនូវអានុភាពនៃអំពើនោះចំពោះ P។ ការបញ្ញត្តិបែបនេះស្របនឹងសង្គមប្រតិបត្តិការ។ CC369 គឺជាបញ្ញត្តិមួយដែលត្រូវបានធ្វើឡើងដោយគិតដល់ចំណុចទាំងនេះ។ បន្ទាប់មក ក្នុងករណីដែលមិនបានទទួលនូវសច្ចានុមតិទេ O នឹងខកចិត្ត ដូច្នេះ គេផ្តល់ចំពោះ O នូវសិទ្ធិទាមទារឱ្យA (អ្នកតំណាងដោយគ្មានសិទ្ធិ) ដែលបានប្រព្រឹត្តអំពើដោយគ្មានសិទ្ធិតំណាងនោះទទួលខុសត្រូវ។ ស្តីពីបញ្ហានេះ នឹងពន្យល់លំអិតខាងក្រោមនេះ។

### 6.2 សិទ្ធិផ្តល់សច្ចានុមតិរបស់សាមីខ្លួន និង សិទ្ធិដាស់តឿន ព្រមទាំងសិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត

#### 6.2.1 សិទ្ធិផ្តល់សច្ចានុមតិរបស់សាមីខ្លួន

ដូចដែលបានពន្យល់ខាងលើនេះហើយ សាមីខ្លួនអាចផ្តល់សច្ចានុមតិ ដើម្បីធ្វើឱ្យអានុភាពនៃអំពើតំណាងដោយគ្មានសិទ្ធិរបស់ P ធ្លាក់ទៅលើខ្លួន។ នេះគេហៅថា សិទ្ធិផ្តល់សច្ចានុមតិ។ ការផ្តល់សច្ចានុមតិ គឺត្រូវធ្វើតាមរយៈការបង្ហាញឆន្ទៈចំពោះ O (CC370 កថាខ័ណ្ឌទី 1)។ ទោះជា

បានផ្តល់សច្ចានុមតិចំពោះ A ក៏ដោយ ក៏មិនច្បាស់ថា ដំណឹងនោះនឹងទៅដល់ O ទេ ម្ល៉ោះហើយ អាចធ្វើឱ្យឋានៈរបស់ O ពុំមានស្ថិរភាពបាន។ ដើម្បីផ្តល់សច្ចានុមតិ Pគ្រាន់តែប្រាប់ទៅ O ថា ខ្លួននឹងទទួលនូវអានុភាពនៃអំពើតំណាងដោយគ្មានសិទ្ធិទៅ បានហើយ។

ពេលដែលបានផ្តល់សច្ចានុមតិហើយ អានុភាពនៃអំពើតំណាងរបស់ A ក៏សុពលភាពប្រតិសកម្ម (CC370 កថាខ័ណ្ឌទី 2 វាក្យខ័ណ្ឌទី 1)។ តាមធម្មតា ទោះបីជាបានផ្តល់សច្ចានុមតិចំពោះអំពើដែលគ្មានសុពលភាពក៏ដោយ ក៏គ្មានអានុភាពប្រតិសកម្មទេ (សូមមើលកំណត់ក្នុង CC357) ក៏ប៉ុន្តែ ចំពោះការផ្តល់សច្ចានុមតិនៃការតំណាងដោយគ្មានសិទ្ធិ មិនមានអ្វីដែលធ្វើឱ្យខូចផលប្រយោជន៍ជាពិសេសដល់ O ទេ ហើយណាមួយទំនាក់ទំនងគតិយុត្តក៏មានភាពងាយស្រួលដែរ ដូច្នេះ គេទទួលស្គាល់នូវអានុភាពប្រតិសិកម្ម។ លើសពីនេះ ក្នុងករណីដែលអានុភាពប្រតិសកម្មនោះធ្វើឱ្យខូចផលប្រយោជន៍ដល់តតិយជន គឺមិនអាចអះអាងចំពោះតតិយជននោះបានទេ (CC370 កថាខ័ណ្ឌទី 2 វាក្យខ័ណ្ឌទី 2)។ គឺមិនត្រូវទទួលស្គាល់នូវអានុភាពប្រតិសកម្មដោយមិនគិតដល់សុវត្ថិភាពនៃប្រតិបត្តិការឡើយ។

តើត្រូវធ្វើយ៉ាងណាឱ្យមានតុល្យភាពរវាងការការពារសុវត្ថិភាពក្នុងកិច្ចប្រតិបត្តិការ (ការការពារសុវត្ថិភាពថាមវន្ត(dynamic))និង ការការពារម្ចាស់សិទ្ធិ (ការការពារសុវត្ថិភាពឋិតិវន្ត(static)) ? នេះគឺជាបញ្ហាមូលដ្ឋាននៃនីតិឯកជន។ ប្រសិនជាចង់ឱ្យសេដ្ឋកិច្ចទីផ្សារមានដំណើរការសកម្ម ត្រូវលំអៀងទៅខាងការពារសុវត្ថិភាពថាមវន្ត។

6.2.2 សិទ្ធិដាស់តឿន និងសិទ្ធិលុបចោលរបស់ភាគីម្ខាងទៀត

រហូតដល់ពេលដែលមានការផ្តល់សច្ចានុមតិ ឬពេលដែលបានបដិសេធមិនផ្តល់សច្ចានុមតិ អានុភាពនៃអំពើតំណាងមានដែរឬទេនោះ មិនទាន់ជាក់ច្បាស់ទេ ដូច្នេះ Oមានឋានៈអស្ថិរភាព។ ក្នុងសេដ្ឋកិច្ចទីផ្សារ គេទាមទារឱ្យ "កិច្ចប្រតិបត្តិការមានភាពរលូន" ដូច្នេះ អស្ថិរភាពនេះគឺផ្ទុយនឹងការទាមទារនៃសេដ្ឋកិច្ចទីផ្សារនេះ។ ម្ល៉ោះហើយ ដើម្បីបំបាត់នូវស្ថានភាពស្ទើរស្ទើរបែបនេះ គេក៏ទទួលស្គាល់នូវសិទ្ធិដាស់តឿន និងសិទ្ធិលុបចោលរបស់ O។

CC370 កថាខ័ណ្ឌទី 3 មានចែងទទួលស្គាល់នូវសិទ្ធិដាស់តឿនរបស់ O គឺ O អាចដាស់តឿនឱ្យ A ធ្វើសេចក្តីសម្រេចថា ផ្តល់ ឬមិនផ្តល់សច្ចានុមតិច្បាស់លាស់ ដោយកំណត់អំឡុងពេលសមស្របមួយ ហើយបើសិនជាមិនបានទទួលចម្លើយច្បាស់លាស់ក្នុងអំឡុងពេលនោះពីAទេ ត្រូវចាត់ទុកថា Aបានបដិសេធមិនផ្តល់សច្ចានុមតិ។ ម្យ៉ាងទៀត ពុំមានវិធីអ្វីកំណត់ច្បាស់លាស់អំពី

"អំឡុងពេលសមស្រប" នេះទេ។ ដូច្នេះត្រូវពិចារណាដល់ស្ថានភាពនានា ដូចជាទម្លាប់ជុំវិញកិច្ចប្រតិបត្តិការនោះ ជាអាទិ៍។ លើសពីនេះ បើសិនជាពុំមានចម្លើយទេ ការចាត់ទុកថាបានបដិសេធនេះ គឺដោយសារតែជាគោលការណ៍ គេមិនទទួលស្គាល់នូវអានុភាពនៃអំពើតំណាងដោយគ្មានសិទ្ធិទេ។

CC370 កថាខ័ណ្ឌទី4 ចែងអំពីសិទ្ធិលុបចោលរបស់ O ដែលមានខ្លឹមសារថា រហូតដល់ពេលដែលA បានផ្តល់សច្ចានុមតិ មានន័យថា ឱ្យតែមានស្ថានភាពស្ទើស្ទើរ Oអាចលុបកិច្ចសន្យាចោលបាន។ មាត្រានេះបានចែងថា "រហូតដល់ពេលដែលបានផ្តល់សច្ចានុមតិ" តែបើសិនជាបានបដិសេធមិនផ្តល់សច្ចានុមតិវិញ ស្ថានភាពស្ទើស្ទើរនោះក៏បានដោះស្រាយរួចរាល់ហើយ ដូច្នេះហើយ ដោយយោងតាមមូលហេតុដូចខាងលើនេះដែរ ក្រោយពេលនោះ មិនត្រូវទទួលស្គាល់ឱ្យ O មានសិទ្ធិលុបចោលទេ។ លើសពីនេះ បើសិនជាមានការបដិសេធមិនផ្តល់សច្ចានុមតិ អានុភាពនៃអំពើតំណាងមិនមែនធ្លាក់ទៅលើ A ទេ ហើយគឺមានន័យដូចគ្នានឹងការប្រើសិទ្ធិលុបចោលដែរ ម្ល៉ោះហើយ មិនចាំបាច់ទទួលស្គាល់សិទ្ធិលុបចោលទេ។

### 6.3 ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

ក្នុងករណីដែល P មិនបានផ្តល់សច្ចានុមតិ តើឋានៈរបស់ O ទៅជាយ៉ាងណាដែរ ?

ក្នុងករណីដែល Pមិនបានផ្តល់សច្ចានុមតិ O មានតែឈប់ប្រតិបត្តិការនឹង P។ ជាលទ្ធផលនៃការឈប់ប្រតិបត្តិការនឹង P Oនឹងអស់ចំណាយក្នុងការចរចារក្នុងប្រតិបត្តិការនេះ ឬបាត់បង់នូវឱកាសប្រតិបត្តិការនឹងអ្នកដទៃទៀត ដែលជាការខូចខាតរបស់ O ដូច្នេះបើសិនជាពុំមានវិធានការអ្វីដើម្បីធ្វើបដិទាននូវការខូចខាតបែបនេះទេ គេនឹងឈប់មានជំនឿទៅលើរបបតំណាងនេះ។ វិធានការនេះគឺការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិនេះឯង(សូមមើលCC371)។

P អាចទាមទារឱ្យAទទួលខុសត្រូវចំពោះអំពើតំណាងដោយគ្មានសិទ្ធិ ដែលជាមូលហេតុនៃការខូចខាតខាងលើនេះបាន។ ទោះជា Aពុំមានកំហុសក្នុងការតំណាងដោយគ្មានសិទ្ធិនេះក៏ដោយ ក៏មិនអាចរួចផុតពីការទទួលខុសត្រូវនេះបានឡើយ។ ដើម្បីរក្សានូវជំនឿទៅលើរបបតំណាងនេះ គេបានតម្រូវឱ្យមានការទទួលខុសត្រូវដោយគ្មានកំហុស។ ក៏ប៉ុន្តែ ក្នុងករណីដែល O បានដឹងថាការតំណាងនោះជាការតំណាងដោយគ្មានសិទ្ធិ O ក៏ដឹងដែរថា អាចមានករណីដែលមិនអាចទទួលនូវសច្ចានុមតិពី P បាន ហេតុនេះហើយ ក្នុងករណីនេះ Oមិនអាចទាមទារឱ្យAទទួលខុសត្រូវបានឡើយ (CC371 វាក្យខ័ណ្ឌទី 2)។ ម្យ៉ាងទៀត បើសិនជាការដែល A បានធ្វើអំពើតំណាងដោយគ្មានសិទ្ធិដោយគ្មានកំហុស តែ O មិនបានដឹងថា Aគ្មានសិទ្ធិតំណាង ដោយមានកំហុស

ទៅវិញ O ក៏មិនអាចទាមទារឱ្យ A ទទួលខុសត្រូវបានដែរ (CC371 វាក្យខ័ណ្ឌទី 3)។ ទោះជាតម្រូវឱ្យ A ទទួលខុសត្រូវដោយគ្មានកំហុសក៏ដោយ តែបើសិនជា Aគ្មានកំហុស រីឯ O មានកំហុសទៅវិញ យើងមិនចាំបាច់ជួយសង្គ្រោះ O រហូតដល់ករណីបែបនេះទេ។

ក្នុងករណីដែលអ្នកតំណាងដោយគ្មានសិទ្ធិ ទទួលខុសត្រូវ ស្តីពីកិច្ចសន្យាដែលពាក់ព័ន្ធនឹងអំពើតំណាងដោយគ្មានសិទ្ធិនោះ តើ A ត្រូវទទួលខុសត្រូវក្នុងការអនុវត្ត ឬត្រូវទទួលខុសត្រូវក្នុងការសងសំណងនៃការខូចខាត គឺជាជម្រើសរបស់ O (CC371 វាក្យខ័ណ្ឌទី 1)។

ស្តីពីអំពើតំណាងរបស់ A ដែលបានប្រកាសថា ខ្លួននឹងធ្វើសកម្មភាពឱ្យ P ក្រោមគោលការណ៍ប្រកាសថានឹងធ្វើសកម្មភាពឱ្យបុគ្គលដែលខ្លួនតំណាង ដោយសារតែអ្នកតំណាងនោះគ្មានសិទ្ធិ ដូច្នេះអានុភាពនៃការតំណាងនោះមិនធ្លាក់ទៅលើ A បានទេ។ នេះគឺដោយសារតែ O បានប្រតិបត្តិការដោយយល់ថា Pជាភាគីម្ខាងទៀតនៃកិច្ចសន្យា។ តើត្រូវទាមទារឱ្យទទួលខុសត្រូវក្នុងការអនុវត្ត ឬទាមទារឱ្យទទួលខុសត្រូវនូវសំណាងនៃការខូចខាត គឺជាជម្រើសរបស់ O ។ ម្យ៉ាងទៀត អាចមានករណីដែលមិនអាចទាមទារឱ្យអនុវត្តកាតព្វកិច្ចបានឡើយ ដូចជាករណីដែលជាកិច្ចសន្យាដែលមានវត្ថុជាក់លាក់ណាមួយជាកម្មវត្ថុនៃកិច្ចសន្យា ជាដើម។

## 7 ការតំណាងដែលមានលក្ខណៈជារូបភាព

ទោះជាករណីតំណាងដោយគ្មានសិទ្ធិក៏ដោយ បើសិនជាមានស្ថានភាពដែលធ្វើឱ្យ O ជឿជាក់ថា Aមានសិទ្ធិតំណាង តាមរយៈទស្សនៈនៃកិច្ចប្រតិបត្តិការ (មើលពីក្រៅទៅ អាចជឿទុកចិត្តបាន) ហើយPមានវិភាគទានក្នុងការបង្កើតស្ថានភាពដែលធ្វើឱ្យ O មានជំនឿថាAមានសិទ្ធិតំណាងនោះ (មានវិភាគទានក្នុងការបង្កើតរូបភាពខាងក្រៅ) ក្នុងករណីបែបនេះ O ដែលសង្ឃឹមថា ខ្លួនអាចបង្កើតកិច្ចប្រតិបត្តិការនឹង P ហើយអាចសម្រេចតាមការសង្ឃឹមរបស់ខ្លួននោះបាននឹងមានជំនឿទៅលើរបបតំណាងខ្លាំងជាងការទទួលស្គាល់នូវការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ។ របបតំណាងដែលមានលក្ខណៈជារូបភាពនេះ គឺជាវិធីមួយដែលអាចធ្វើឱ្យ O បានសម្រេចតាមសេចក្តីសង្ឃឹមរបស់ខ្លួនបាន (CC372)។

ក្នុងការតំណាងដោយមានលក្ខណៈជារូបភាពក៏ដូចគ្នាដែរ គឺត្រូវពិចារណានិងប្រៀបធៀបរវាងការការពារសុវត្ថិភាពនៃកិច្ចប្រតិបត្តិការ និងការការពារសុវត្ថិភាពឋិតិវន្ត។ ដំបូង គឺគេគិតអំពីការការពារម្ចាស់សិទ្ធិ (ការការពារសុវត្ថិភាពឋិតិវន្ត) ជាមុន ក៏ប៉ុន្តែបើសិនជាការការពារនេះធ្វើឱ្យបាត់បង់នូវសុវត្ថិភាពនៃកិច្ចប្រតិបត្តិការធ្ងន់ធ្ងរ ត្រូវតែការពារភាគីម្ខាងទៀតនៃកិច្ចប្រតិបត្តិការខ្លាំងជាការពារម្ចាស់សិទ្ធិ។ ម្ល៉ោះហើយ ក្នុងការតំណាងដែលមានលក្ខណៈជារូបភាព ដោយពិចារណាទៅលើល័ក្ខខ័ណ្ឌ "ភាពត្រឹមត្រូវនៃជំនឿទុកចិត្តទៅលើរូបភាពខាងក្រៅ" របស់ O និង "វិភាគទានទៅលើការបង្កើតរូបភាពខាងក្រៅ" របស់ P ទោះជាអំពើតំណាងរបស់ Aដែលគ្មាន

សិទ្ធិតំណាងក៏ដោយ ក៏ត្រូវឱ្យ P ទទួលនូវអានុភាពគតិយុត្តនោះ។

ស្តីពី “ភាពគួរឱ្យជឿទៅលើរូបភាពខាងក្រៅ” របស់ O នេះ ក្នុង CC372 គេប្រើពាក្យ ភាគីOជឿជាក់ថា អ្នកតំណាងមានសិទ្ធិតំណាងចំពោះកិច្ចសន្យានោះ ហើយគ្មានកំហុសក្នុងការជឿនោះ ហើយស្តីពីបញ្ហាថា តើមានកំហុស ឬគ្មាននោះ យើងត្រូវធ្វើការវិនិច្ឆ័យទៅតាមទម្លាប់ធម្មតានៃប្រតិបត្តិការនោះដែរ។

ស្តីពី “វិភាគទានទៅលើការបង្កើតរូបភាពខាងក្រៅ” របស់ P វិញ ក្នុង CC372 មានចែងនូវឧទាហរណ៍បីប្រភេទ។

ប្រភេទទី១ គេហៅថា “ការតំណាងហួសសិទ្ធិ” ឬ “ការតំណាងដែលមានលក្ខណៈជារូបភាពដែលហួសសិទ្ធិអំណាច” ហើយគឺជាអំពើតំណាងដែលហួសទំហំសិទ្ធិតំណាងដែលម្ចាស់សិទ្ធិបានផ្តល់ទៅឱ្យអ្នកតំណាង (CC372 កថាខ័ណ្ឌទី 1)។ គេឃើញមានការតំណាងហួសសិទ្ធិនេះក្នុងករណីដែលមានការផ្តល់សិទ្ធិតំណាងដោយក្រដាសស (ដោយគ្មានល័ក្ខខ័ណ្ឌ) នៅពេលដែល P បានផ្តល់សិទ្ធិទៅឱ្យ A ។ ប្រសិនជាមានការធ្វើហួសសិទ្ធិបែបនេះ អំពើតំណាងនោះ គឺជាការតំណាងដោយគ្មានសិទ្ធិ។ ក៏ប៉ុន្តែ តាមរយៈការផ្តល់សិទ្ធិតំណាងដែលជាមូលដ្ឋាន (គេហៅថាសិទ្ធិតំណាងមូលដ្ឋាន) គេបានបង្កើតនូវភាពខាងក្រៅមួយដែលធ្វើឱ្យការតំណាងដោយគ្មានសិទ្ធិនោះ ដូចជាមានសិទ្ធិតំណាងទៅវិញ ដូច្នេះP មានវិភាគទានទៅលើបញ្ហានេះ។ តើសិទ្ធិអ្វីខ្លះដែលជាសិទ្ធិតំណាងមូលដ្ឋាន ? ស្តីពីចំណុចនេះ យើងត្រូវពិចារណាថែមទៀត។ បើសិនជាយើងបញ្ចូលទាំងការធ្វើអំពើជំនួសជាក់ស្តែង (ស្រដៀងនឹងការតំណាង) ឬការតំណាងនៃអំពើរដ្ឋបាល ទៅក្នុងសិទ្ធិតំណាងមូលដ្ឋានទៅ គឺជាការទទួលស្គាល់យ៉ាងទូលំទូលាយនូវការតំណាងដែលមានលក្ខណៈជារូបភាព ដូច្នេះ ការប្រើប្រព័ន្ធតំណាងនេះ នឹងអាចទទួលនូវហានិភ័យខ្ពស់ខ្លាំងពេក។ ប្រសិនជាគោលដៅនៃការតំណាងដោយមានលក្ខណៈជារូបភាពគឺ សុវត្ថិភាពនៃប្រតិបត្តិការ ជាគោលការណ៍ គប្បីចាត់ទុកថា សិទ្ធិតំណាងនៃសកម្មភាពគតិយុត្តតាមផ្លូវនីតិឯកជន គឺជាសិទ្ធិតំណាងមូលដ្ឋាន។

ប្រភេទទី២ គេហៅថា “ការតំណាងដោយសិទ្ធិដែលបានរលត់” ឬ “ការតំណាងដែលមានលក្ខណៈជារូបភាពក្រោយពេលបាត់បង់សិទ្ធិតំណាង”។ នេះគឺជាករណីដែលក្រោយពេលដែលសិទ្ធិតំណាងបានរលត់ អ្នកដែលបានធ្វើជាតំណាង នៅតែធ្វើសកម្មភាពក្នុងនាមជាតំណាងដដែល (CC372 កថាខ័ណ្ឌទី 2)។ អាចមានឧទាហរណ៍ស្តីពីការតំណាងដោយសិទ្ធិដែលបានរលត់ ដូចជាករណីដែល P ដែលជាអ្នកគ្រប់គ្រងរោងចក្របានផ្តល់សិទ្ធិទៅឱ្យបុគ្គលិករបស់ខ្លួនឈ្មោះ A ទៅទិញគ្រឿងសម្រាប់តម្លើងម៉ាស៊ីន ក៏ប៉ុន្តែក្រោយមក A បានឈប់ពីក្រុមហ៊ុន។ ការបានផ្តល់សិទ្ធិតំណាងនេះ គឺជាវិភាគទានមួយក្នុងការបង្កើតរូបភាពខាងក្រៅរបស់ P ។ សិទ្ធិតំណាងដែលបានរលត់ គឺជាសិទ្ធិតំណាងមូលដ្ឋាន ហេតុនេះហើយ មានការជជែកច្រើន ដូចករណីនៃការតំណាង

ហួសសិទ្ធិដែរ។

ប្រភេទទី៣គេហៅថា ការតំណាងដោយមានលក្ខណៈជារូបភាពតាមរយៈការបង្ហាញនូវការផ្ដល់សិទ្ធិតំណាង។ នេះគឺជាករណីដែលបុគ្គលម្នាក់បានបង្ហាញថា ខ្លួនបានទទួលសិទ្ធិតំណាង ក៏ប៉ុន្តែតាមការពិត ជននោះមិនបានទទួលសិទ្ធិតំណាងទេ តែបានធ្វើអំពើតំណាង (CC372 កថាខ័ណ្ឌទី 3)។ ស្ដីពីការបង្ហាញថា បានទទួលសិទ្ធិតំណាង គេអាចទទួលស្គាល់ថា មានវិភាគទានទៅលើការបង្កើតរូបភាពខាងក្រៅរបស់ P។ តើការបង្ហាញបែបណា ទើបអាចក្លាយជា "ការបង្ហាញថាបានទទួលសិទ្ធិតំណាង" ? ចំណុចនេះ យើងត្រូវសម្រេចទៅតាមទម្លាប់នៃកិច្ចប្រតិបត្តិការ។

ប្រភេទដែលបានលើកឡើងនៅក្នុង CC372 គឺជាឧទាហរណ៍មួយចំនួនប៉ុណ្ណោះ។ ដូច្នេះ អាចមានករណីក្រៅពីនេះទៀត ដែលមានរូបភាពខាងក្រៅដែលបង្ហាញថាមានសិទ្ធិតំណាង ហើយ P មានវិភាគទានក្នុងការបង្កើតស្ថានភាពនោះ ហើយប្រសិនជាបានជឿទៅលើរូបភាពខាងក្រៅនោះដោយគ្មានកំហុស គេទទួលស្គាល់ថា ជាការតំណាងដែលមានលក្ខណៈជារូបភាព។ អាចមានករណីដែលប្រភេទនៃការតំណាងដែលមានលក្ខណៈជារូបភាពនោះ ជាន់គ្នាក៏មានដែរ។

## 8 ការបង្កើតការតំណាងដែលមានលក្ខណៈជារូបភាព និង ការទទួលខុសត្រូវរបស់អ្នកតំណាងដោយគ្មានសិទ្ធិ

បើសិនជាការតំណាងដែលមានលក្ខណៈជារូបភាពត្រូវបានបង្កើតឡើង O អាចអះអាងចំពោះ P ថា ខ្លួនបានទទួលនូវអានុភាពគតិយុត្តនៃអំពើតំណាងដោយគ្មានសិទ្ធិរបស់A បាន។ ហើយជាលទ្ធផល Oអាចមានឋានៈដូចគ្នានឹងករណីនៃការតំណាងដែលមានសិទ្ធិ។ តើ Oអាចអះអាងចំពោះ P នូវទំនាក់ទំនងគតិយុត្តដែលកើតឡើងពីអំពើតំណាងដែលគ្មានសិទ្ធិ ដោយលើកឡើងនូវមូលហេតុថា ជាការតំណាងដែលមានលក្ខណៈជារូបភាព ហើយព្រមជាមួយគ្នានេះ តើអាចទាមទារឱ្យ A ទទួលខុសត្រូវស្ដីពីការតំណាងដែលគ្មានសិទ្ធិនេះបានដែរឬទេ?